# ការសិក្សាឆ្លងដែន:  ករណីសិក្សានិស្សិតខ្មែរទទួលអាហារូបករណ៍ម្ចាស់ក្សត្រីយ៍សិរិនថននៅសាកលវិទ្យាល័យមហាសារ៉ាខាម

## Transnational Migrant Studies: Case Study *“Cambodian Students that have gotten Sirindhorn’s Scholarship at Mahasarakham University”*

Mr.Hem Samphos[1]


**บทคัดย่อ**

บทความนี้ มุ่งที่จะทำความเข้าใจวิถีคนข้ามแดนและเครือข่ายทางสังคมของนักเรียนทุนพระราชทานของสมเด็จพระเทพรัตนราชสุดาฯ สยามบรมราชกุมารี ในประเทศไทย โดยเน้นนิสิตกัมพูชาที่เรียนในมหาวิทยาลัยมหาสารคาม เป็นกรณีศึกษา ประเด้นหลักของงานวิจัยนี้ คือต้องการรับรู้วิถีชีวิตความเป็นอยู่ของนิสิต ความสัมพันธ์ เครือข่ายทางสังคม รวมทั้งผลประโยชน์ต่างๆ ที่นิสิตได้รับในช่วงเรียน และหลังสำเร็จการศึกษา เพื่อมีแนวทางต่างๆ พัฒนาโครงการในโอกาสต่อไป การศึกษานี้ จะใช้แนวคิดลักษณะข้ามชาติ (Transnationalism) ในด้านการศึกษา หรือเรียกได้ว่า **คนข้ามแดนศึกษา** (Transnational Migration Studies) ของ Leo Chavez บูรณาการกับแนวคิดกลยุทธ์ปฏิบัติการในชีวิตประจำวันของ De Certeau

ผลการศึกษาในงานวิจัยนี้ พบว่า นิสิตกัมพูชา มีความยากลำบากพอสมควรในการเรียนในช่วงแรกๆ เนื่องจากการใช้ภาษาไทย การเข้าร่วมกิจกรรมต่างๆ การทำการบ้าน และการลงทะเบียน เป็นต้น ส่วนปัญหาชีวิตความเป็นอยู่ประจำวัน พวกเขายังไม่สามารถปรับตัวกับอาหารไทยได้ดี เนื่องจากปัญหาการใช้เครื่องผสมในการทำกับข้าว (โดยเฉพาะอาหารเผ็ด) กับที่พักอาศัยก็เป็นปัญหาหนึ่งที่พวกเขารู้สึกยากลำบาก เพราะต้องอยู่ร่วมกัน และใช้ห้องน้ำร่วม ซึ่งบางครั้งอาจจะมีการรบกวนคนอื่นๆ โดยการส่งเสียงดังๆ ซึ่งทำให้เสียสมาธิในการศึกษาได้ รวมทั้งปัญหาการคบกลุ่มเพื่อนก็เป็นปัญหาเช่นเดียวกัน เนื่องจากนิสิตบางคน ไม่ค่อยคบกับเพื่อนคนไทย โดยอ้างว่า มีนิสิตกัมพูชาเรียนด้วยกันแล้ว และพวกเขาอาจจะยังรู้สึกว่า ภาษาไทยพวกเขายังไม่ดี ซึ่งไม่กล้าพูดคุยกับเพื่อนๆ คนไทย สำหรับปัญหาในการปรับตัวทางด้านวัฒนธรรมนั้น เป็นปัญหาสุดท้ายที่นิสิตกัมพูชา รู้สึกว่า มีความยาก ลำบากด้วย แต่ไม่หนักหน่วงเท่าใด เนื่องจากไทยและกัมพูชา มีประเพณีวัฒนธรรมใกล้เคียงกัน อย่างไรก็ตาม ผลประโยชน์ที่พวกเขาได้รับจากทุนพระราชทานฯ นั้น ได้สร้างความรู้ ความสามารถ ประสบการณ์ และอนาคตที่ดี โดยเฉพาะการสร้างความสัมพันธ์ทางเครือข่ายทางสังคมให้ดียิ่งขึ้นด้วย


**คำสำคัญ**: คนข้ามแดนศึกษา กลยุทธ์ปฏิบัติการในชีวิตประจำวัน

---

[1] Head of Thai Department, Institute of Foreign Languages, Royal University of Phnom Penh

## Abstract

This article aims to study the ways of transnational migrant and social network of Khmer Student that get Sirindhorn' Scholarship at Mahasarakham University. The mains point of study need to understand the everyday life practice, communication, relationship, social network, and advantages that students have gotten in study period and graduated for finding some strategies to follow up the project. This study, writer uses 2 approaches such as Transnational Migration Studies and Tactics of Everyday Life Practices.

The results of study showed that Cambodian students have some problems in their study in the first time such as using Thai language, participating activities, doing assignment and registering etc. For daily of life, they can't adapt with Thai foods well because of ingredients (chilly food and low quality of rice). One more, the dormitory is one problem that they feel stress because they need to live with other students. The last one is friend relationship, some Cambodian students don't contact with Thai friends because they have Cambodian students in Classroom and they feel their Thai language not well. Hence, they don't want to speak with them. For the adaptation in Culture is the last problem that Cambodian students have faced too. However, the advantages from that scholarship build their knowledge capacity experience and good future, especially the social network of relationship.


**Key Words:** Transnational Migration Studies, Tactics in Everyday Life Practice

## សេចក្តីផ្តើម

### ប្រវត្តិរបស់ព្រះរាជគម្រោងឧបត្ថម្ភអាហារូបករណ៍ម្ចាស់ក្សត្រីយ៍សិរិនថន

ព្រះរាជគម្រោងឧបត្ថម្ភម្ចាស់ក្សត្រីយ៍សិរិនថនចាប់ផ្តើមចាប់ឆ្នាំ 2004-2008 សម្រាប់ផ្តល់អាហារូបករណ៍ដល់គ្រូនិងដល់សិស្ស វិទ្យាល័យកំពង់ឈើទាលដែលរៀនចប់ថ្នាក់ទី 9 ថ្នាក់ទី 12 និងសិស្សវិជ្ជាជីវៈឆ្នាំទី 3។ ចាប់ពីឆ្នាំ 2009 ដល់បច្ចុប្បន្ន ព្រះរាជគម្រោងឧបត្ថម្ភបានផ្តល់ដល់សិស្សនិស្សិតខ្មែរទូទៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនផ្តោតលើវិទ្យាល័យកំពង់ឈើទាលតែមួយទៀតទេ។ ការរៀបចំការជ្រើសរើសនិស្សិតមានការសហការគ្នាជាមួយក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានចំនួននិស្សិតកើនឡើងជារៀងរាល់ឆ្នាំ។



និស្សិតខ្មែរសាកលវិទ្យាល័យមហាសាខាម

និស្សិតខ្មែរបានមករៀនបន្តនៅសាកលវិទ្យាល័យមហាសារ៉ាខាមចាប់ផ្តើមពីឆ្នាំ2008 រហូតដល់បច្ចុប្បន្នមានកម្រិតបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ក្នុងជំនាញផ្សេងៗ ដូចជា អប់រំ ថៃសិក្សា គណនេយ្យនិងគ្រប់គ្រង ទេសចរណ៍និងបដិសណ្ឋារកិច្ច គិលានុបដ្ឋាកយិការ និងវិស្វករ ជាដើម។

ពីមួយឆ្នាំទៅមួយឆ្នាំ និស្សិតមានចំនួនកាន់តែច្រើនឡើង និស្សិតខ្មែរនៅសាកល-វិទ្យាល័យមហាសារ៉ាខាមបានយល់ស្របក្នុងការបង្កើតសមាគមនិស្សិតមូលនិធិម្ចាស់ក្សតីយ៍សិរិនថនសាកលវិទ្យាល័យមហាសារ៉ាខាម (Cambodian Students Association of Sirindhorn’s Scholarship at Mahasarakham University (CASS-MSU))

យើងសង្កេតឃើញថា ការបំលាស់ប្តូរទីតាំងការសិក្សារបស់និស្សិតពីខេត្តមកទីក្រុង និងពិសេស ការឆ្លងដែនទៅសិក្សានៅក្រៅប្រទេសជាចំណុចមួយគួរឲ្យចាប់អារម្មណ៍សម្រាប់ការសិក្សាស្រាវជ្រាវក្នុង បច្ចុប្បន្ន ព្រោះយើងឃើញថាការឆ្លងដែន (Transnationalism) មានគោលដៅសំខាន់ៗ ក្នុងការស្វែងរកផលប្រយោជន៍ទាំងការសិក្សានិងការងារ។ អ្នកស្រាវជ្រាវភាគច្រើនចង់ស្វែងយល់ពីបញ្ហាពលករឆ្លងដែន ដែលត្រូវជួបបញ្ហាប្រឈមអ្វីខ្លះ ជីវភាពរស់នៅយ៉ាងដូចម្តេច និងផលប្រយោជន៍ផ្សេងៗ ដែលពួកគេទទួលបាន។ ចំណែកក្នុងកិច្ចការស្រាវជ្រាវមួយនេះ យើងចង់ស្វែងយល់ពីបញ្ហារបស់និស្សិតដែលមកបន្តការសិក្សានៅក្រៅប្រទេសមានបញ្ហាប្រឈមយ៉ាងដូចម្តេច មានជីវិតរស់នៅដូចម្តេច និងការដោះស្រាយជីវភាពរស់នៅរបស់ពួកគេយ៉ាងណាដែរ ដើម្បីអាចរស់នៅនិងសិក្សានៅសាកលវិទ្យាល័យរហូតទទួលបានជោគជ័យ។ យើងនឹងលើកយកករណីសិក្សានិស្សិតដែលរៀនបន្តនៅសាកលវិទ្យាល័យមហា

សារ៉ាខាមមកសិក្សាស្វែងយល់អំពីបញ្ហាខាងលើនេះ។

## វត្ថុបំណងរបស់ការស្រាវជ្រាវ

កិច្ចស្រាវជ្រាវនេះយើងត្រូវការសិក្សាស្វែងយល់ពីប្រយោជន៍ដែលទទួលបានពីគម្រោងព្រះរាជឧបត្ថម្ភអាហារូបករណ៍ម្ចាស់ក្សត្រីយ៍សិរិនថនដល់ព្រះរាជាណាចក្រកម្ពុជាផ្នែកអប់រំ ដោយមានគោលបំណងដូចតទៅនេះ៖

1. ដើម្បីសិក្សាប្រវត្តិ ជីវភាពរស់នៅ និងការសម្របខ្លួនរបស់និស្សិតខ្មែរក្នុងសាកលវិទ្យាល័យមហាសារ៉ាខាមក្នុងឋានៈជាអ្នកឆ្លងដែន។

2. ដើម្បីសិក្សាប្រយោជន៍នៃគម្រោងព្រះរាជឧបត្ថម្ភអាហារូបករណ៍ម្ចាស់ក្សត្រីយ៍សិរិនថនដល់និស្សិតខ្មែរ។

## ព្រំដែនការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះ នឹងសិក្សាឆ្លុះបញ្ចាំងឲ្យឃើញពីជីវភាពរស់នៅរបស់និស្សិតខ្មែរ និងប្រយោជន៍ដែលទទួលអាហារូបករណ៍ព្រះរាជឧបត្ថម្ភម្ចាស់ក្សត្រីយ៍សិរិនថននៅសាកលវិទ្យាល័យមហាសារ៉ាខាម។ ពេលវេលាស្រាវជ្រាវគឺក្នុងអំឡុងពេលដែលអ្នកស្រាវជ្រាវបានមកសិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យមហាសារ៉ាខាម ឆ្នាំ2012-2013។

## ដំណើរការស្រាវជ្រាវ

ដំណើរការស្រាវជ្រាវនេះ យើងនឹងប្រើប្រាស់របៀបការស្រាវជ្រាវផ្នែកគុណភាព ដោយផ្តោតលើការសម្ភាសន៍បែបស៊ីជម្រៅ (Key Informant) និងការសង្កេតដោយមានការចូលរួម ( Participant Observation)។

## ទ្រឹស្តីសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ

កិច្ចស្រាវជ្រាវនេះ យើងនឹងប្រើប្រាស់ទ្រឹស្តីចំនួន 2 សំខាន់ ដើម្បីវិភាគទិន្នន័យគឺ ទ្រឹស្តីយុទ្ធសាស្រ្តក្នុងការប្រតិបត្តិការសម្រាប់ជីវភាពប្រចាំថ្ងៃ (Tactics in Everyday Life Practice) និងទ្រឹស្តីការសិក្សាឆ្លងដែន (Transnational Migration Studies)។

### ទ្រឹស្តីវិធីសាស្រ្តក្នុងការប្រតិបត្តិការសម្រាប់ជីវភាពប្រចាំថ្ងៃ (Tactics in Everyday Life Practice)

ទ្រឹស្តីវិធីសាស្រ្តក្នុងការប្រតិបត្តិការសម្រាប់ជីវភាពប្រចាំថ្ងៃ ជាទ្រឹស្តីដែលលោក De Certeau (1984) ទទួលឥទ្ធិពលនិងសិក្សាបន្តពីលោក Bourdieu ក្នុងស្នាដៃ Outline of a Theory of Practice ដោយ លោក De Certeau ពន្យល់ថា ការប្រតិបត្តិការជីវិតប្រចាំថ្ងៃគឺជាការប្រតិបត្តិការដែលមានន័យយ៉ាងសាមញ្ញប្រៀបបានការទាញខ្សែកំណត់ព្រំដែនរបស់ក្មេងដែលជា Autistic ។ការទាញខ្សែខាងលើជាផ្លូវដែលក្មេងនោះធ្វើតាមហើយទៅតាមតក្ករបស់ពួកគេដោយផ្ទាល់និងប្រយោល។ លោក De Certeau បានបែងចែកការប្រតិបត្តិការជា 2 លក្ខណៈគឺ យុទ្ធសាស្រ្ត (Strategy) និងវិធីសាស្រ្ត (Tactics) ។ យុទ្ធសាស្រ្ត (Strategy) មានន័យថាការគ្រប់គ្រងរបស់ភាគីដែលមានអំណាចឬអ្វីដែលត្រូវការមានទីតាំងច្បាស់លាស់ដូចជា អ្នកជំនួញ កងទ័ព ទីក្រុងឬស្ថាប័នវិទ្យាសាស្រ្ត ជាដើម។ យុទ្ធសាស្រ្តអាច

ថាជាទីតាំងអាចគួសជារង្វង់បានយ៉ាងពិតប្រាកដនិងមានឫសគល់ដែលអាចឲ្យកើតនូវទំនាក់ទំនងផ្សេងៗ ជាមួតនឹងអ្វីដែលនៅខាងក្រៅដូចជា គោលដៅ (target) និងទង្វើ (treat)។ ទាំងនេះអាចរៀបចំបានដូចជា អតិថិជន គូប្រកួតប្រជែង សត្រូវ ជនបទនៅជុំវិញទីក្រុង គោលដៅនិងគោលបំណងរបស់កិច្ចការស្រាវជ្រាវនេះជាដើម។ ក្នុងការរៀបចំយុទ្ធសាស្ត្រត្រូវធ្វើឲ្យមានហេតុផល ប្រការទីមួយដើម្បីញែកទីតាំងរបស់វាដែលជាទីតាំងរបស់អំណាចនិងសេចក្តីត្រូវការឲ្យចេញពីអ្វីផ្សេងៗ។ ការមានហេតុផលបែបវិទ្យាសាស្ត្រ នយោបាយ និងកងទ័ពបានបង្កើតឡើងពីទម្រង់យុទ្ធសាស្ត្រនេះ។ ចំណែកវិធីសាស្ត្រ (Tactics) មានន័យថា អ្វីដែលផ្ទុយពីយុទ្ធសាស្ត្រគឺជាការស្វែងរកទំនាក់ទំនងដែលមិនមានទីតាំងពិតប្រាកដ មិនអាចកំណត់ព្រំដែនបាននូវអ្វីដែលនៅខាងក្រៅ។ ទីតាំងរបស់វិធីសាស្ត្រជាទីតាំងរបស់អ្នកដទៃនិងវិធីសាស្ត្រជាសិល្បៈរបស់អ្នកទន់ខ្សោយដូចជាការធ្វើសង្គ្រាមដែលមានកំលាំងតិចជាង ជ្រៀតជ្រែកដោយការបំបែកកំលាំងចូលទៅក្នុងទីតាំងដែលគ្រប់គ្រងដោយភាគីមានអំណាច ដើម្បីកុំឲ្យសង្កេតបានងាយស្រួលជាដើម។ លោក De Certeau យល់ឃើញថា វិធីសាស្ត្រអាចឲ្យឃើញពីការប្រតិបត្តិការជីវិតប្រចាំថ្ងៃបាន ដូចជា ការអាន ការធ្វើដំណើរ ការបរិភោគ ការធ្វើម្ហូប ។ល។ ដែលមានន័យក្នុងការតស៊ូ ការតវ៉ា និងការរៀបចំសម្ពន្ធភាពផ្នែកអំណាច (ไชยณรงค์ เศรษฐเชื้อ. 2009: 27)។

## ទ្រឹស្តីការសិក្សាឆ្លងដែន

**(Transnational Migration Studies)**

បាតុភូត "ការឆ្លងដែន" (Transnational) បានក្លាយជាមធ្យោបាយសំខាន់ក្នុងការបង្កើតការផ្លាស់ប្តូរទំនាក់ទំនងខាងសង្គម នយោបាយ សេដ្ឋកិច្ច និងវប្បធម៌យ៉ាងប្របូកប្របល់និងទូលាយ។ លក្ខណៈឆ្លងដែន (Transnationalism) ជាបាតុភូតផ្លាស់ប្តូរខាងសង្គមសម័យថ្មីក្នុងពិភពលោកតាំងពីទស្សវត្ស 1980 បានស្ថិតនៅក្នុងសម័យសាកលភាវូបនីយកម្ម (Globalization)។

លក្ខណៈការឆ្លងដែននិយមជាដំណើរការហូរចូលរបស់មនុស្ស ទំនិញ ប្រាក់ដើមទុន ចំណេះដឹង និងវប្បធម៌ឆ្លងព្រំដែនជាប់គ្នានិងមិនជាប់គ្នាក្នុងបរិវេណទីតាំងណាមួយដោយមានតួសំដែងដែលមិនមែនជារដ្ឋ។ (Nina Glick Schiller and Fouron, 2008: 324-344 និង เดชา ตั้งสีฟ้า, 2549: 23) បានបែងចែកលក្ខណៈការឆ្លងដែនជា 3 ប្រភេទ គឺ 1) លក្ខណៈឆ្លងដែនពីខាងលើ (Transnationalism from above) 2) លក្ខណៈឆ្លងដែនពីខាងក្រោម (Transnationalism from below) 3) លក្ខណៈឆ្លងដែនភាគតិច (Minor Transnationalism)។ នៅក្នុងការសិក្សាស្រាវជ្រាវនេះ យើងនឹងសិក្សាករណីនិស្សិតខ្មែរនៅសាកលវិទ្យាល័យមហាសារ៉ាខាមក្នុងលក្ខណៈឆ្លងដែនភាគតិច។

Leo Chavez (1992, 2007) ជានវិទ្យាស្រាវជ្រាវពីការសិក្សាឆ្លងដែន (transnational migration studies) បានលើកឡើងថា សារៈសំខាន់របស់ការសិក្សានេះស្ថិតនៅលើការ

ព្យាយាមវិភាគនិងយល់ពីរឿងរ៉ាវផ្សេងៗ ដែលកើតឡើងឆ្លងកាត់បទពិសោធឬការគិតផ្សេងៗរបស់អ្នកចំណាកស្រុកពលករក្រៅស្រុក អ្នកចូលប្រទេសខុសច្បាប់ ដូចជាករណីអ្នកចំណាកស្រុកជនជាតិម៉ិចស៊ីកូក្នុងសហរដ្ឋ អាមេរិក។ ជាមួយគ្នានេះដែរ លោកវ៉ាក់សាន់ បញ្ញាកែវ បាននាំយកគំនិតនេះទៅពន្យល់ពីការសិក្សាពីករណីជនជាតិលីឆ្លងដែន (วสันต์ ปัญญาแก้ว. 2012: 11)។ ទោះបីជាយ៉ាងណា ការសិក្សារបស់លោក Leo Chavez និងលោកវ៉ាក់សាន់ បញ្ញាកែវ បានផ្តោតទៅលើពលករឆ្លងដែនខុសច្បាប់តែប៉ុណ្ណោះ។ ចំណែកការសិក្សានេះវិញ ផ្តោតទៅលើនិស្សិតខ្មែរដែលទទួលបានអាហារូបករណ៍មកសិក្សានិងរស់នៅក្នុងប្រទេសថៃស្របច្បាប់។

## ការរស់នៅនិងការសម្របខ្លួនរបស់និស្សិត

ការផ្លាស់ប្តូរទីកន្លែងរស់នៅពីកន្លែងមួយទៅកន្លែងមួយទៀតឬការឆ្លងដែន ត្រូវចេះសម្របខ្លួនឲ្យចុះសម្រុងជាមួយកន្លែងនោះ ដើម្បីធ្វើឲ្យជីវិតរស់នៅប្រកបដោយក្តីសុខ ដូចករណីរបស់និស្សិតខ្មែរដែលមកបន្តការសិក្សានៅក្នុងសាកលវិទ្យាល័យមហាសារ៉ាខាម។ ពួកគេត្រូវចេះដោះស្រាយបញ្ហាផ្សេងៗក្នុងការសម្របខ្លួនដើម្បីរស់នៅនិងសិក្សារៀនសូត្រក្នុងសាកលវិទ្យាល័យបាន។ ជាមួយគ្នានេះ ពួកគេក៏ត្រូវប្រឈមនឹងបញ្ហាមួយចំនួនក្នុងការសម្របខ្លួន ព្រោះការធ្វើដំណើរចេញពីប្រទេសខ្លួនហើយមករស់នៅប្រទេសថៃជារឿងមួយលំបាកណាស់ក្នុងការសម្របខ្លួនឲ្យសមស្របជាមួយសង្គមថ្មី។ ដូចនេះ និស្សិតខ្មែរមានបញ្ហាអ្វីខ្លះ និងពួកគេមានវិធីក្នុងការសម្របខ្លួនបានយ៉ាងដូចម្តេច? ក្នុងកិច្ចការស្រាវជ្រាវនេះ យើងនឹងសិក្សាពីការសម្របខ្លួនរបស់និស្សិតជា 2 ផ្នែកសំខាន់គឺ ការសម្របខ្លួនផ្នែកខាងក្នុង (Internal adaptation) និងការសម្របខ្លួនផ្នែកខាងក្រៅ (External adaptation) របស់និស្សិត។ យើងសិក្សាការសម្របខ្លួនទាំងពីរផ្នែកខាងលើនេះប្រៀបធៀបជាមួយនឹងកំលាំងជម្រុញពីខាងក្នុង (Internal Demands)និងកំលាំងជម្រុញចេញពីខាងក្រៅ (External Demands) របស់ Lazarus។ ការសម្របខ្លួនផ្នែកខាងក្នុងសំដៅទៅលើការសម្របចិត្ត ចំណេះដឹង សេចក្តីត្រូវការ ដែលបង្ហាញតាមរយៈចិត្តគំនិតនិង ការសម្របខ្លួនផ្នែកខាងក្រៅសំដៅទៅលើការសម្របខ្លួនដើម្បីឲ្យអាចរស់នៅជាមួយអ្នកដទៃបាន មានទំនាក់ទំនងជាមួយអ្នកដទៃ។ ពោលគឺបរិស្ថានដែលនៅជុំវិញខ្លួន។ ដូចនេះ យើងនឹងបែងចែកបញ្ហាក្នុងការសម្របខ្លួនរបស់និស្សិតខ្មែរជា 3 សំខាន់គឺ ការសម្របខ្លួនក្នុងការសិក្សា ការសម្របខ្លួនក្នុងរស់នៅប្រចាំថ្ងៃ និងការសម្របខ្លួនផ្នែកវប្បធម៌។

## ការសម្របខ្លួនក្នុងការសិក្សា

ការសម្របខ្លួនក្នុងការសិក្សារបស់និស្សិតខ្មែរក្នុងការសិក្សាបានបែងចែកចេញជា 2 ផ្នែកគឺការសម្របខ្លួនក្នុងថ្នាក់រៀននិងការសម្របខ្លួនក្រៅថ្នាក់រៀន។

### ក. ការសម្របខ្លួនក្នុងថ្នាក់រៀន

ការរៀនជាមួយនិស្សិតថៃដោយប្រើប្រាស់ភាសាថៃជាភាសាគោលក្នុងការរៀននោះជាការលំបាកសម្រាប់និស្សិតខ្មែរថ្មី ដោយសារពួកគាត់នៅមិនទាន់អាចយល់អំពីការពន្យល់មេរៀនក្នុងថ្នាក់បានល្អ។ តួយ៉ាង លោកហ៊ុន តុលា និស្សិតឆ្នាំទី 1 បាននិយាយថា "*នៅពេលខ្ញុំកំពុងរៀនក្នុងថ្នាក់ ពេលខ្លះខ្ញុំមានអារម្មណ៍តានតឹង*

*ព្រោះមិនអាចយល់អ្វីដែលរៀននិងពេលខ្លះមិនអាចឆ្លើយតបសំនួរដែលលោកគ្រូសួរ.....”* ។ ជាមួយគ្នានេះ លោកហ៊ុន តុលា បាននិយាយបន្ថែមទៀតថា “ *ខ្ញុំមានអារម្មណ៍អៀនខ្មាសនៅពេលខ្ញុំនិយាយហើយ និស្សិតថៃខ្លះសើចព្រោះការបញ្ចេញសម្លេង របស់ខ្ញុំមិនច្បាស់មិនដូចជនជាតិថៃ។ ទោះបីជាយ៉ាងណា លោកគ្រូនិងមិត្តៗ បានផ្តល់កំលាំងចិត្ត បានធ្វើឲ្យខ្ញុំព្យាយាមនិងសម្របខ្លួនបានល្អឡើងក្នុងពេលបច្ចុប្បន្ន”*។

ជាទូទៅ ការសិក្សាក្នុងថ្នាក់រៀនរមែងមានបញ្ហាក្នុងផ្តល់សារនិងយល់ពីមុខវិជ្ជានីមួយៗ។ និស្សិតគ្រប់រូបតែងតែជួបបញ្ហានេះជានិច្ចព្រោះក្នុងថ្នាក់រៀនត្រូវមានការលើកសំនួរនិងឆ្លងសំនួររវាងគ្រូជាមួយនិស្សិត និង រវាងនិស្សិតជាមួយនិស្សិត។ ជាពិសេសសម្រាប់និស្សិតបរទេសស្ទើរតែមានការលំបាកក្នុងអំឡុងពេលចាប់ផ្តើមរៀនមុខវិជ្ជាណាមួយ។ ដូចនេះ ពួកគាត់ទើបកើតភាពតានតឹងក្នុងការសិក្សា។ លោក Roger (สุภาพรรณ โคตรจรัส. 2524 อ้างอิงมาจาก Roger 1951) បានលើកឡើងថា ការសម្របខ្លួនដែលមិនចុះសម្រុងគ្នាពីគំនិតខ្លួនឯងនិងបទពិសោធ នឹងនាំមកភាពតានតឹងផ្នែកអារម្មណ៍។ នេះមានន័យថា ភាពតានតឹងរមែងកើតឡើងក្នុងអំឡុងពេលដែលនិស្សិតកម្ពុជាទើបមកប្រឈមមុខក្នុងស្ថានភាពការសិក្សាថ្មីដែលពួកគាត់មិនទាន់បទពិសោធក្នុងការសម្របខ្លួនឲ្យស្របតាមសង្គមការសិក្សាថ្មី។ ជាពិសេសនិស្សិតភាគច្រើន ពួកគេទើបតែរៀនចប់ពីវិទ្យាល័យដែលមិនទាន់បទពិសោធក្នុងការរៀននៅសាកលវិទ្យាល័យ។ ទាំងនេះក៏ជាកត្តាមួយដែលបង្កើតបរិយាកាសតានតឹងដល់ពួកគេផងដែរ។ លោកហ៊ុន តុលា បាននិយាយបន្ថែមទៀតថា “ *នៅពេលចូលរៀនដំបូងក្នុងបន្ទប់រៀនខ្ញុំមានអារម្មណ៍តានតឹងព្រោះមិនអាចស្តាប់យល់ពីអ្វីដែលគ្រូបង្រៀននិងមិត្តភក្តិនិយាយ តែក្រោយពីសិក្សាអស់មួយរយៈពេល ក៏ចាប់ផ្តើមសម្របបាន”* ។នេះបញ្ជាក់ឲ្យឃើញថា និស្សិតចាប់ផ្តើមសម្របខ្លួនក្នុងបន្ទប់បានក្រោយពីគេបានយកចិត្តទុកដាក់ពីគ្រូបង្រៀននិងការជួយជ្រោមជ្រែងពីមិត្តភក្តិផងដែរ គឺពួកគាត់អាចឆ្លើយតបនិងសាកសួរពីអ្វីដែលគេមិនយល់ទៅគ្រូនិងមិត្តភក្តិហើយកាន់តែជឿជាក់លើខ្លួនឯងក្នុងការរៀនសូត្រកាន់តែខ្លាំងឡើង។

**ខ. ការសម្របខ្លួនក្រៅថ្នាក់រៀន**

ក្រៅពីការសិក្សាក្នុងថ្នាក់រៀនហើយ និស្សិតខ្មែរត្រូវរៀននៅក្រៅថ្នាក់រៀនផងដែរដូចជា និស្សិតត្រូវធ្វើកិច្ចការផ្ទះ ត្រូវចូលបណ្ណាល័យ និងធ្វើសកម្មភាពផ្សេងៗ ដោយសារនៅឆ្នាំទី 1 មានមុខវិជ្ជាច្រើន ទើបធ្វើឲ្យនិស្សិតខ្លះបានបង្ហាញការលំបាកក្នុងការធ្វើកិច្ចការផ្ទះ ដែលអ្នកខ្លះរៀន 9 មុខវិជ្ជាក្នុងមួយសប្តាហ៍។ លោក ថៃលី និស្សិតឆ្នាំទី 1 បានលើកឡើងថា *“ខ្ញុំរៀនដល់ទៅ 9 មុខវិជ្ជាក្នុងមួយសប្តាហ៍និងមានកិច្ចការផ្ទះគ្រប់មុខវិជ្ជា ដែលខ្ញុំចាំបាច់ត្រូវធ្វើរាល់ថ្ងៃ។ ក្រៅពីកិច្ចការផ្ទះហើយ ខ្ញុំត្រូវចូលរួមសកម្មភាពរបស់និស្សិតផងដែរ តែពេលខ្លះខ្ញុំមិនបានចូលរួមសកម្មភាពជាមួយពួកគាត់ដោយសារត្រូវការពេលធ្វើកិច្ចការផ្ទះល្អជាង”*។ ការរៀបចំធ្វើសកម្មភាពរបស់និស្សិតក្នុងសាកលវិទ្យាល័យជាសកម្មភាពមួយ ដើម្បីធ្វើឲ្យនិស្សិតមានបទពិសោធ មានសេចក្តីក្លាហាន ចេះធ្វើការងារជាក្រុម និងបង្កើតទំនាក់ទំនងល្អជាមួយគ្នា។ តាមការសង្កេត យើងឃើញថា នៅក្នុងអំឡុងពេលបើកបវេសនកាលដំបូងៗ និស្សិតថៃបានរៀបចំ

សកម្មភាពជាច្រើនដូចជា សកម្មភាពទទួលសិស្សប្អូន ការបោះជុំរំ ឬសកម្មភាពរបស់មហាវិទ្យាល័យ។ សកម្មភាពទាំងនេះ និស្សិតគ្រប់រូបត្រូវចូលរួមហាត់នៅក្នុងពេលល្ងាចឬយប់ក្រោយពីចេញពីរៀន។ លោកថៃលី បាននិយាយបន្ថែមទៀតថា "*សកម្មភាពទាំងនេះមានប្រយោជន៍សម្រាប់និស្សិត ដែលនៅកម្ពុជា មិនសូវមានសកម្មភាពដូចនេះ ចឹងហើយទើបខ្ញុំមិនសូវចាប់អារម្មណ៍ប៉ុន្មាន ហើយផ្តោតលើការរៀនប្រសើរជាង*"។ ទាំងនេះបញ្ជាក់ឲ្យឃើញថា ទំនាក់ទំនងការរៀនក្រៅថ្នាក់រៀនរបស់និស្សិតខ្មែរគឺផ្តោតទៅមុខវិជ្ជាដែលគេសិក្សាជាជាងសកម្មភាពថ្មីៗដែលមាននៅក្នុងប្រទេសថៃ។ ការមិនសូវមានបទសោធធ្វើសកម្មភាពទាំងនេះក៏កត្តាមួយមិនជំរុញឲ្យពួកគាត់ចូលចិត្ត ហើយចាំបាច់ត្រូវការពេលវេលដើម្បីសម្របខ្លួនផងដែរ។

## ការសម្របខ្លួនក្នុងជីវិតរស់នៅប្រចាំថ្ងៃ

បញ្ហាការសម្របខ្លួនក្នុងជីវិតរស់នៅប្រចាំថ្ងៃក្នុងអត្ថបទស្រាវជ្រាវនេះនឹងលើកយកការសម្របខ្លួនជាមួយទីកន្លែងស្នាក់នៅ ម្ហូបអាហារ និងការសេពគប់មិត្តភក្តិ។

### ក. ការសម្របខ្លួនជាមួយនឹងកន្លែងស្នាក់នៅ

សាកលវិទ្យាល័យមហាសារ៉ាខាមបានរៀបចំឲ្យនិស្សិតខ្មែរស្នាក់នៅក្នុងអន្តេវាសិកដ្ឋានរបស់សាកលវិទ្យាល័យ ដោយមិនចំណាយថ្លៃអ្វីទាំងអស់ ដូចជា ថ្លៃកន្លែងស្នាក់នៅ ថ្លៃទឹក ថ្លៃភ្លើង និង អ៊ិនធើណេត ជាដើម។ ទោះបីជាយ៉ាងណា និស្សិតខ្លះនៅមិនទាន់សម្របខ្លួនឯងបានក្នុងការរស់នៅអន្តេវាសិកដ្ឋាន ដែលមានចំនួនមនុស្សច្រើននិងប្រើប្រាស់បន្ទប់ទឹករួម។ ទាំងអស់នេះ ពួកគាត់មិនធ្លាប់រស់នៅកាលពីនៅកម្ពុជា។ ជាធម្មតា នៅកម្ពុជា ពួកគាត់រស់នៅជាមួយឪពុកម្តាយនិងមិនធ្លាប់រស់នៅក្នុងស្ថានភាពបែបនេះ។ មួយវិញទៀត ក្នុងឆ្នាំសិក្សា 2012 អន្តេវាសិកដ្ឋានរបស់សាកលវិទ្យាល័យទីតាំងថ្មី (ម.ใหม่) មិនមានគ្រប់គ្រាន់សម្រាប់និស្សិត។ ដូចនេះ ពួកគាត់ត្រូវទៅស្នាក់នៅទីតាំងចាស់ (ม.เก่า) ។ តែពួកគាត់ភាគច្រើនរៀននៅទីតាំងថ្មី ដូចនេះត្រូវជិះឡានឈ្នួលដើម្បីទៅរៀន ដែលធ្វើឲ្យពួកគាត់មានការលំបាក។ លោក ឆាយណា និស្សិតបរិញ្ញាបត្រឆ្នាំទី 1 បាននិយាយថា "*ខ្ញុំមិនចង់ស្នាក់នៅសាកលវិទ្យាល័យទីតាំងចាស់នោះទេ ព្រោះខ្ញុំត្រូវទៅរៀនទីតាំងថ្មី បើនៅទីនេះខ្ញុំត្រូវចំណាយថ្លៃឡាន និងខាតពេលវេលា*"។ នេះបញ្ជាក់ឲ្យឃើញថា ការឲ្យនិស្សិតស្នាក់នៅទីតាំងណាមួយមិនសមស្របអាច បង្កការលំបាកដល់និស្សិតក្នុងធ្វើដំណើរ ពិសេសថ្លៃធ្វើដំណើរ ព្រោះពួកគាត់ជានិស្សិតអាហារូបករណ៍ដែលប្រាក់ឧបត្ថម្ភប្រចាំខែគ្រប់គ្រាន់សម្រាប់ចំណាយអាហារនិងសៀវភៅសិក្សាតែប៉ុណ្ណោះ។ ពិសេសទៅទៀត ការធ្វើដំណើរប្រឈមមុខនឹងគ្រោះថ្នាក់ ខាតពេលវេលាផងដែរ ព្រោះពួកគាត់ជានិស្សិតថ្មីដែលមិនទាន់មានបទពិសោធគ្រប់គ្រាន់ក្នុងការរស់នៅនៅឡើយ។

### ខ.ការសម្របខ្លួនជាមួយនឹងម្ហូបអាហារ

ម្ហូបអាហារជារឿងសំខាន់បំផុតសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ តែម្ហូបអាហាររបស់ប្រទេសនីមួយៗ និងតំបន់នីមួយៗ រមែងមានភាពប្រហាក់ប្រហែគ្នានិងខុសគ្នា។ បើសិនម្ហូបអាហារមានលក្ខណៈប្រហាក់ប្រហែលគ្នា ការសម្របខ្លួនក្នុងការហូបចុកមិនមានជាបញ្ហាអ្វីនោះទេ។ ប៉ុន្តែបើសិនមានភាពខុសគ្នានឹងបង្កើតការលំបាកចំពោះមនុស្សចំណូលថ្មីជាមិនខាន ព្រោះ

ម្ហូបអាហារមិនសមស្របជាមួយស្ថានភាពរាងកាយរបស់ពួកគេ ដែលអាចផ្តល់ផលប៉ះពាល់ដល់សុខភាព។ ទាំងនេះនឹងធ្វើឲ្យពួកគេមិនអាចធ្វើកិច្ចការផ្សេងៗបានរលូនល្អ ដោយសារបញ្ហាសុខភាពត្រូវការមើលថែទាំនិងព្យាបាល។ សម្រាប់និស្សិតបរទេស ពួកគេត្រូវសម្របខ្លួនក្នុងការទទួលទានអាហារឲ្យសមស្រប ដើម្បីធ្វើឲ្យការសិក្សាពួកគេទទួលបានជោគជ័យ។ នេះមានន័យថាពួកគេមិនចាំបាច់បារម្ភបញ្ហាសុខភាពព្រោះសុខភាពមិនល្អ ការសិក្សាក៏មិនល្អដូចគ្នាផងដែរ។ សម្រាប់បញ្ហាការបរិភោគ និស្សិតខ្មែរដែលមករៀននៅសាកលវិទ្យាល័យមហាសារ៉ាខាមនិងសាកលវិទ្យាល័យដទៃទៀតរមែងមានបញ្ហាម្ហូបថៃដែលមានរសជាតិហឹរ ដែលម្ហូបស្ទើរគ្រប់មុខសុទ្ធតែដាក់ម្ទេសជាគ្រឿងផ្សំ។ ដូចនេះពេលកុំម៉្មង់ម្ហូបនិស្សិតត្រូវប្រាប់ចុងភៅមុនថាមិនដាក់ម្ទេស មិនហឹរ ឬដាក់ម្ទេសតិចតួច។ បើពួកគេនៅមួយរយៈពេលពួកគាត់នឹងអាចសម្របបានជាមួយម្ហូបហឹរទាំងនេះ។

**គ.ការសម្របខ្លួនជាមួយមិត្តភក្តិថ្មី**

ការសម្របខ្លួនជាមួយមិត្តថ្មីត្រូវមានការផ្លាស់ប្តូរនិងត្រូវស្គាល់ស្វែងយល់ពីគ្នាដែលផ្តល់ផលល្អក្នុងការសម្របខ្លួន។ លោក Gronlund បានសិក្សាពីបញ្ហាការរៀនការបង្រៀនថ្នាក់ឧត្តមសិក្សារបស់និស្សិតសាកលវិទ្យាល័យឃើញថានិស្សិតមានបញ្ហាទំនាក់ទំនងជាមួយបុគ្គលដទៃរមែងមានបញ្ហាក្នុងការរៀន ដែលការមិនចុះសម្រុងជាមួយមិត្តភក្តិអាចធ្វើឲ្យពួកគេមិនទទួលជោគជ័យក្នុងការសិក្សា ធ្វើឲ្យកើតអារម្មណ៍តានតឹងនិងមិនមានក្តីសុខ (Gronlund. 1959:176) ។ និស្សិតខ្មែរក្នុងអំឡុងពេលដំបូងពួកគាត់ភាគច្រើនមិនអាចនិយាយភាសាថៃបានទើបធ្វើឲ្យពួកគាត់មិនសូវចង់និយាយភាសាថៃជាមួយមិត្តជនជាតិថៃ។ ជាមួយគ្នានេះនិស្សិតខ្លះរៀនជាមួយមិត្តភក្តិខ្មែរដូចគ្នា ដូចនេះពួកគេនិយាយភាសាខ្មែរជាមួយគ្នាដែលជាហេតុធ្វើឲ្យការបង្កើតមិត្តថ្មីត្រូវការពេលវេលាយូរបន្តិច។ លោកឆាយណា បានប្រាប់ថា " *ខ្ញុំមិនចង់និយាយជាមួយនិស្សិតថៃព្រោះខ្លាចគេស្តាប់មិនយល់"* ។តែខុសពីលោកឆាយណា លោកហ៊ុនតុលា បាននិយាយថា "*ការសេពគប់មិត្តជនជាតិថៃជារឿងធម្មតា ខ្ញុំបានជជែកជាមួយគ្នាយ៉ាងជិតស្និទ្ធ ហើយពួកគេបានជួយបង្រៀនភាសាថៃឲ្យខ្ញុំផងទៀត។"* ការសម្របខ្លួនរបស់និស្សិតជាមួយមិត្តភក្តិថ្មីអាស្រ័យលើការស្វែងយល់គ្នារបស់និស្សិតបើគេគិតថាលំបាកអាចត្រូវការពេលវេលាមួយសមស្របដើម្បីសម្របខ្លួន។

**បញ្ហាផ្នែកវប្បធម៌**

វប្បធម៌របស់ប្រទេសនីមួយៗរមែងមានភាពខុសគ្នា។ ដូចនេះហើយ ទើបលោក Cohen បានលើកទ្រឹស្តីផ្នែកការសម្របខ្លួនមានលក្ខណៈមូលដ្ឋានលើវប្បធម៌ដែលជាមធ្យោបាយសំខាន់ក្នុងការសម្របខ្លួនរបស់មនុស្ស។ នេះមានន័យថា ការយល់និងរៀនសូត្រពីវប្បធម៌ណាមួយជាផ្លូវមួយធ្វើឲ្យមនុស្សអាចនៅក្នុងសង្គមនោះបានដោយការសម្របខ្លួនឲ្យចុះសម្រុងនិងសមស្របតាមសង្គមនោះ។ ប្រទេសកម្ពុជា និងប្រទេសថៃជាប្រទេសជិតខាងនឹងគ្នានិងមានវប្បធម៌ប្រហាក់ប្រហែលគ្នា។ ដូចនេះ ការសម្របខ្លួនផ្នែកវប្បធម៌ទើបមិនសូវជាមានភាពលំបាកលំបិនប៉ុន្មានសម្រាប់និស្សិតខ្មែរដូចជាការរាក់ទាក់គ្នាដោយការសំពះ ការគោរពព្រះពុទ្ធសាសនាដូចគ្នាជាដើម។ ដូចនេះ ការធ្វើកម្មវិធី

ខាងសាសនាមិនបង្កជាបញ្ហារបស់និស្សិតខ្មែរនិងនិស្សិតថៃនោះទេ ដែលពួកគេអាចចូលរួមនិងធ្វើកម្មវិធីផ្សេងៗ ជាមួយគ្នាបាន ដោយមិនមានក្ដីកង្វល់ពីបញ្ហាសាសនា។ ម្យ៉ាងវិញទៀត និស្សិតក្នុងសាកលវិទ្យាល័យ ដោយក្នុងនោះនិស្សិតខ្មែរផងដែរ បានរៀបចំកម្មវិធីសំដែងផ្សេងៗ ទាក់ទងនឹងវប្បធម៌របស់ខ្លួននៅក្នុងឱកាសកម្មវិធីសំខាន់ៗ របស់សាកលវិទ្យាល័យដូចជាពិធីចូលនៅក្នុងអន្តេវាសិកដ្ឋាន ពិធីខួបរបស់សាកលវិទ្យាល័យជាដើម។ និស្សិតខ្មែរបានរៀបចំក្រុមសំដែងរបាំ ល្បែងប្រជាប្រិយឬការច្រៀងចម្រៀងឲ្យនិស្សិតថៃនិងបរទេសបានស្គាល់និងដឹង។ ចំណែកនិស្សិតថៃនិងបរទេសបានសំដែងវប្បធម៌របស់ខ្លួនផងដែរ។ ការបង្ហាញពីវប្បធម៌របស់ប្រទេសនីមួយៗ នោះបានធ្វើឲ្យនិស្សិតទទួលបានចំណេះដឹងនិងបទពិសោធល្អក្នុងការរស់នៅបន្តទៀត។

ទោះបីជាយ៉ាងណា សម្រាប់និស្សិតខ្មែរដែលទើបតែមករៀននៅសាកលវិទ្យាល័យ (និស្សិតឆ្នាំទី 1) ខ្លះមានអារម្មណ៍ថាសម្របខ្លួនមិនសូវបានល្អ ដោយសារពួកគេមានអារម្មណ៍ខ្មាសអៀន ដូចជាពួកគាត់ត្រូវចូលរួមហាត់សមដើម្បីសំដែររបាំជាមួយនិស្សិតបងៗ ដែលពួកគេមិនធ្លាប់បានធ្វើពីមុនមក។ និស្សិតធីតា បានលើកឡើងថា *"នាងខ្ញុំមានអារម្មណ៍ខ្មាសអៀននៅពេលចូលរួមសំដែងជាមួយមិត្តភក្តិក្នុងអំឡុងពេលដំបូង ព្រោះខ្ញុំមិនដែលហាត់សំដែងនិងឡើងសំដែងក្នុងកម្មវិធីផ្សេងៗ ដូចនេះ កាលពីនៅកម្ពុជា ដែលពេលខ្លះ ខ្ញុំមិនអាចហាត់បានល្អដូចក្រុមបងៗ។*

## ប្រយោជន៍ដែលនិស្សិតខ្មែរទទួលបានពីព្រះរាជគម្រោងឧបត្ថម្ភ

ព្រះរាជគម្រោងឧបត្ថម្ភអាហារូបករណ៍ម្ចាស់ក្សត្រីយ៍សិរិនថនបានផ្ដល់ឱកាសល្អក្នុងការអភិវឌ្ឍចំណេះដឹងនិងបទពិសោធដ៏ល្អ ដែលនិស្សិតបានទទួលប្រយោជន៍ទាំងក្នុងពេលសិក្សានិងក្រោយបញ្ចប់ការសិក្សា។ កិច្ចការស្រាវជ្រាវនេះបង្ហាញថា និស្សិតមានសេចក្ដីសប្បាយរីករាយណាស់ដែលបានទទួលអាហារូបករណ៍មករៀននៅប្រទេសថៃ ហើយក៏ជាឱកាសដ៏ល្អក្នុងការសិក្សាក្រៅប្រទេស ដើម្បីអភិវឌ្ឍខ្លួនឆ្ពោះទៅរកសម័យសាកលភាវូបនីយកម្ម (Globalization) ។ និស្សិតខ្មែរបានប្រាប់ពីប្រយោជន៍នៃអាហារូបករណ៍នេះ មានដូចជា ថ្លៃចំណាយទូទៅ ចំណេះដឹង បទពិសោធ ទំនាក់ទនង និងការងារ។ ផលប្រយោជន៍ទាំងនេះ បានមកពីសហប្រតិបត្តិការយ៉ាងល្អរវាងរដ្ឋាភិបាលកម្ពុជានិងថៃ ជាពិសេសម្ចាស់ក្សត្រីយ៍សិរិនថនដែលទ្រង់រៀបចំព្រះរាជគម្រោងឧបត្ថម្ភអាហារូបករណ៍ដល់និស្សិតខ្មែរ។

### ថ្លៃចំណាយទូទៅ

កម្ពុជានៅជាប្រទេសកំពុងអភិវឌ្ឍ (Developing Country) ដែលត្រូវការធនធានមនុស្សចំនួនច្រើន ដើម្បីជួយអភិវឌ្ឍប្រទេសជាតិឲ្យរីកចម្រើន។ ជាមួយគ្នានេះ ប្រជាជនភាគច្រើនមានជីវភាពមិនទាន់ល្អប្រសើរប៉ុន្មាននោះទេ (ជាកសិករ)។ ដូចនេះការជួយឧបត្ថម្ភការសិក្សារៀនសូត្រដល់កូនមកសិក្សាក្នុងសាកលវិទ្យាល័យពិតជាបញ្ហាសម្រាប់ពួកគាត់។ និស្សិតដែលទទួលបានអាហារូបករណ៍មានឱកាសល្អដែលពួកគេអាចចូលរៀននៅសាកលវិទ្យាល័យក្នុងប្រទេសថៃ ដោយមិនចាំបាច់ចំណាយលើអ្វី

ទាំងអស់ដូចជា ថ្លៃសាលា ថ្លៃស្នាក់នៅ ថ្លៃភ្លើង និងទឹក។ ជាមួយគ្នានេះ និស្សិតក៏មានប្រាក់ឧបត្ថម្ភប្រចាំខែ (5000 បាតក្នុងមួយខែ) ថ្លៃធានារ៉ាប់រងសុខភាព និងផ្សេងៗ ទៀត។ និស្សិតភាគច្រើនបាននិយាយថា ពួកគេមិនចាំបាច់ប្រាក់ឧបត្ថម្ភពីឪពុកម្តាយនិងមិនសូវគិតពីបញ្ហាចាយវាយប៉ុន្មាននោះទេ។ លោកស៊ីណាត និស្សិតឆ្នាំទី 4 បាននិយាយថា "ខ្ញុំសប្បាយចិត្តដែលបានមករៀននៅប្រទេសថៃ ជាពិសេសនៅសាកលវិទ្យាល័យមហាសារ៉ាខាម ដោយខ្ញុំមិនបាច់បង់ថ្លៃសាលា ថ្លៃសៀវភៅ ថ្លៃស្នាក់នៅ ជាដើម"។

**ចំណេះដឹង**

គោលដៅចម្បងរបស់ព្រះរាជគម្រោងឧបត្ថម្ភអាហារូបករណ៍ ដើម្បីអភិវឌ្ឍចំណេះដឹងឲ្យនិស្សិត ខ្មែរ។ លោក John Dewey (John Dewey,1938) យល់ឃើញថា គុណតម្លៃរបស់ការសិក្សាស្ថិតនៅលើបែបបទនៃការសិក្សាដែលអាចបង្កើតសេចក្តីប្រាថ្នាដ៏ល្អនៅក្នុងខ្លួនបុគ្គល។ ចំណែកការសិក្សារបានផ្តល់នូវមធ្យោបាយជួយធ្វើឲ្យសេចក្តីប្រាថ្នាខាងលើក្លាយជាការពិតបាន ដូចជា អាជីព ការអនុវត្តការងារ និងភាសា។ និស្សិតភាគច្រើនបានបង្ហាញគំនិតថា ការទទួលបានអាហារូបករណ៍មករៀននៅប្រទេសថៃ បានកសាងខ្លួនឲ្យមានចំណេះដឹងខាងជំនាញបានច្បាស់លាស់ ដែលអាចនាំយកទៅធ្វើការងារបានយ៉ាងមានប្រសិទ្ធភាពតាមសេចក្តីត្រូវការរបស់ក្រុមហ៊ុននិងស្ថាប័នផ្សេងៗ។ ក្រៅពីការរៀនក្នុងថ្នាក់ហើយ ពួកគាត់ត្រូវចូលរួមសកម្មភាពនានាទាក់ទងនឹងការរៀនសូត្រនិងការហាត់ការជាប្រចាំ។ ទាំងនេះជាការអភិវឌ្ឍខ្លួនបានយ៉ាងល្អមុននឹងទៅធ្វើការងារក្រោយពីបញ្ចប់ការសិក្សា។ ម្យ៉ាងវិញទៀត និស្សិតភាគច្រើនមានសមត្ថភាពប្រើប្រាស់ភាសាថៃបានល្អដែលពួកគេអាចទាក់ទងគ្នាបានល្អទាំងក្នុងផ្នែកការងារស្រាវជ្រាវនិងការងារទូទៅ។ និស្សិត រៀម ម៉ៅ បានលើកឡើងថា "*ខ្ញុំសំណាងល្អណាស់ដែលបានមករៀននៅសាកលវិទ្យាល័យមហាសារ៉ាខាម ដែលការរៀននៅក្នុងបន្ទប់និងក្រៅបន្ទប់រៀន បានជួយឲ្យខ្ញុំមានចំណេះដឹងច្បាស់លាស់។ ខ្ញុំសង្ឃឹមថា នៅពេលរៀនចប់ ខ្ញុំនឹងត្រឡប់ទៅធ្វើការនៅប្រទេសកម្ពុជា ដើម្បីជួយគ្រួសារនិងអភិវឌ្ឍប្រទេសឲ្យរីកចម្រើន*"។

**បទពិសោធ**

ការស្នាក់នៅនិងរៀននៅក្រៅប្រទេស និស្សិតទទួលបានបទពិសោធច្រើនដូចជា ធ្វើឲ្យខ្លួនឯងក្លាយខ្លួនជាមនុស្សមានទំនួលខុសត្រូវស្វ័យសិក្សា ការរៀបចំការរស់នៅសមរម្យ និងការសម្របខ្លួនឲ្យចុះសម្រុងនៅក្នុងសង្គម ដើម្បីអាចរស់នៅនិងរៀនសូត្របានទទួលជោគជ័យ។ ជាការពិតណាស់ និស្សិតខ្មែរភាគច្រើនជានិស្សិតទើបបញ្ចប់ថ្នាក់វិទ្យាល័យ ដែលពួកគេមានបទពិសោធជីវិតតិចតួចនៅក្នុងសង្គមនៅឡើយ ដែលទាមទារការសម្របខ្លួននិងរៀនសូត្រច្រើន ជាពិសេសការរស់នៅក្រៅប្រទេស។ លោក Spindler (George D. Spindler,1977) បានលើកឡើងថា ការសិក្សាជាវិធីឆ្ពោះទៅរកការរីកចំរើននិងការសម្របខ្លួនរបស់វិធីនេះគឺ ក្មេងត្រូវសម្របខ្លួនឲ្យចូលក្នុងបរិស្ថានដែលមានវប្បធម៌របស់តំបន់និងសង្គម។ មួយវិញទៀត ការសិក្សាជាការផ្សាយវប្បធម៌បន្ត ដែលមានចំណេះដឹង ទស្សនៈ សេនិយម និងទម្រង់ផ្សេងៗ នៃការប្រព្រឹត្ត។ ពោលគឺការសិក្សាធ្វើឲ្យមនុស្សមានវប្បធម៌នោះឯង។ ពេលដំបូងនៃការសិក្សានៅ

ប្រទេសថៃ និស្សិតខ្មែរមានការលំបាកក្នុងការរស់នៅសាកលវិទ្យាល័យ។ តែដោយមានសិក្សាពីវិធីសម្របខ្លួនដូចជា ម្ហូបអាហារ ការរៀនសូត្រ ទើបពួកគេអាចរស់នៅនិងរៀនសូត្រទទួលបានជោគជ័យ។ លោកហៀង សុខា បាននិយាយថា " ខ្ញុំគិតថា ខ្ញុំទទួលបានបទពិសោធច្រើនក្នុងការមករៀនបន្តនៅសាកលវិទ្យាល័យ ទាំងការរៀន ការចុះកម្មសិក្សា ការចូលរួមសកម្មភាពផ្សេងៗ និងស្គាល់ពីតំបន់ផ្សេងៗ នៅក្នុងប្រទេសថៃ"។



និស្សិតខ្មែរចូលរួមសំដែងនៅសាកលវិទ្យាល័យមហាសារ៉ាខាម

**ទំនាក់ទំនង**

ទំនាក់ទនងរវាងមនុស្សជាកត្តាមួយ ដែលបង្កើតឲ្យមានសេចក្ដីសុខ សហការ និង សន្តិភាព។ ដូចនេះ ការដែលនិស្សិតខ្មែរទទួលបានអាហារូបករណ៍មកសិក្សានៅក្នុងប្រទេសថៃ ជាមាគ៌ាមួយក្នុងការជួយលើកស្ទួយទំនាក់ទំនងល្អរវាងកម្ពុជានិងថៃកាន់តែប្រសើរឡើង។ ដូចនឹងគំនិតរបស់ Kneller (George F. Kneller,1965) បានលើកឡើងថា ការសិក្សាគឺជាដំណើរការគ្រប់ប្រភេទ លើកលែងតែដំណើរការផ្ទេកជីវវិទ្យាប៉ុណ្ណោះ ដែលអាចជួយធ្វើឲ្យចិត្ត គំនិត និស្ស័យ និងសមត្ថភាពផ្លូវកាយដល់មនុស្ស។ ក្នុងករណីនេះ ទំនាក់ទំនងល្អរវាងនិស្សិតនិងនិស្សិត គ្រូ មិត្តភក្តិ និងប្រជាជនថៃ នឹងជួយធ្វើឲ្យយល់គ្នានិងលើកស្ទួយទំនាក់ទំនងល្អរវាងប្រទេសកម្ពុជានិងថៃ។ ទោះបីជាប្រទេសទាំងពីរធ្លាប់មានបញ្ហាជាមួយគ្នាក៏ដោយ។ តែការយល់ពីគ្នា អាចជួយដោះស្រាយបញ្ហាបានខ្លះផងដែរ ដែលរដ្ឋាភិបាលមិនអាចចូលដល់ ដូចជា ប្រជាជនតាមតំបន់ និស្សិត សិស្ស និងអ្នកជំនួយ ជាដើម។ លោក សំ លីហ្សា បានបង្ហាញគំនិតថា *"ខ្ញុំរីករាយដែលបានទទួលអាហារូបករណ៍មកប្រទេសថៃ។ សម្រាប់ការមករៀនមិនមែនត្រឹមតែចំណេះដឹងនោះទេ តែយើងអាចបង្កើតទំនាក់ទំនង សហការ និងការស្វែងយល់ពីគ្នាបានយ៉ាងល្អរវាងខ្ញុំ សាស្ត្រាចារ្យ និងនិស្សិតថៃ។ ចំណែកអ្នកលក់ដូរដែលខ្ញុំធ្លាប់ទាក់ទងគ្នា បើមានបញ្ហាអ្វីកើតឡើងរវាងកម្ពុជានិងថៃ ពួកយើងអាចយល់ពីគ្នា សាកសួរគ្នាដូចជាបងប្អូន បើមិនមានសកម្មភាពដូចនេះទេ អាចធ្វើឲ្យកើតបញ្ហាលំបាកដល់និស្សិតជាមិនខាន ពេលមានបញ្ហាព្រំដែនរវាងទាំងពីរប្រទេស។ ដូចនេះ ការបង្កើទំនាក់ទំនងល្អជាគោលដៅមួយរបស់ព្រះរាជគម្រោងផងដែរ។*

**ការងារ**

លោក Theodore (Theodore W. Schultz, 1971) បានលើកឡើងថា ការសិក្សាជាការវិនិយោគទុនជាមួយខ្លួនឯង។ គំនិតនេះជាគំនិតដ៏ល្អដែលអ្នករៀន និស្សិតគ្រប់រូបត្រូវបោះទុនទាំងកំលាំងកាយនិងកំលាំងចិត្ត ដើម្បីស្វែងរកចំណេះដឹងដល់ខ្លួន។ ទោះបីជាលទ្ធផលការសិក្សានោះ មិនបានកើតឡើងភ្លាមៗ ក៏ដោយ។ តែជាការវិនិយោគទុនដ៏វែងឆ្ងាយនិងអាចទទួលបានផលពេញមួយជីវិត។ ទោះបីជាយ៉ាងណា ការវិនិយោគទុនទទួលជោគជ័យបាន លុះត្រាតែមានការជម្រុញផងដែរដូចជាព្រះរាជ

គម្រោងឧបត្ថម្ភអាហារូបករណ៍ដល់និស្សិតខ្មែរ មានឱកាសអភិវឌ្ឍទាំងចំណេះដឹងនិងស្ថានភាពគ្រួសាររបស់ខ្លួនបានល្អប្រសើរឡើង ដោយសារក្រោយពីបញ្ចប់ការសិក្សាហើយ ពួកគាត់អាចរកការងារធ្វើបានសមរម្យ ដែលអាចរកចំណូលដើម្បីជួយឧបត្ថម្ភគ្រួសារបាន។ ការមានការងារធ្វើសមរម្យនិងតាមមុខជំនាញ នឹងជួយធ្វើឲ្យអនាគតរបស់និស្សិតល្អប្រសើរឡើង ក៏ដូចជាការអភិវឌ្ឍប្រទេសជាតិឲ្យរីកចម្រើនទៅមុខផងដែរ។ កញ្ញា វៀង ស៊ីឡុង ជានិស្សិតបញ្ចប់ការសិក្សាឆ្នាំ 2012 មុខជំនាញទេសចរណ៍និងបដិសណ្ឋារកិច្ច បច្ចុប្បន្ន គាត់បានធ្វើការនៅក្រុមហ៊ុនស្រាបៀរសិង្ហ ខេត្តសៀមរាប ដោយទទួលបានប្រាក់ខែក្នុងមួយខែចំនួនប្រហែល ១០០០០ បាត ដែលប្រាក់ខែនេះមានចំនួនច្រើនសម្រាប់និស្សិតដែលទើបបញ្ចប់ការសិក្សានៅប្រទេសកម្ពុជា។ ក្រៅពីនិស្សិតបានធ្វើដំណើរត្រឡប់ធ្វើការងារនៅកម្ពុជាវិញហើយ តែក៏មាននិស្សិតមួយចំនួនបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដូចជាលោក ង៉ោ សុជាតិ និស្សិតបរិញ្ញាបត្រមុខជំនាញទេសចរណ៍និងបដិសណ្ឋារកិច្ច បានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើមុខជំនាញការគ្រប់គ្រងសេដ្ឋកិច្ចធុរកិច្ច នៅសាកលវិទ្យាល័យមហាសារ៉ាខាម។ ដូចនេះ សបញ្ជាក់ឲ្យឃើញថា និស្សិតដែលទទួលបានអាហារូបករណ៍ភាគច្រើនមានអនាគតល្អក្នុងការសិក្សាបន្តនិងស្វែងរកការងារធ្វើ។

## លទ្ធផលការស្រាវជ្រាវ

ការសិក្សានេះ បង្ហាញឲ្យឃើញថា និស្សិតខ្មែរដែលទទួលបានអាហារូបករណ៍ជួបប្រទះនូវបញ្ហាផ្សេងៗ ទាក់ទងនឹងការសម្របខ្លួនក្នុងជីវភាពប្រចាំថ្ងៃនិងការសិក្សា។ ប៉ុន្តែ ពួកគាត់អាចសម្របខ្លួនបានបន្តិចម្តងៗ និងទទួលបានផលប្រយោជន៍យ៉ាងអនេកផងដែរ។ ពួកគាត់អាចកសាងសមត្ថភាព ចំណេះដឹង និងបទពិសោធល្អ ដើម្បីអនាគតពួកគាត់ និងជួយសង្គមជាតិឲ្យរីកចម្រើន។

## សរុបនិងអនុសាសន៍

យើងឃើញថា កិច្ចការស្រាវជ្រាវនេះ បានបង្ហាញពីការរស់នៅរបស់និស្សិតខ្មែរ ការសិក្សា ទំនាក់ទំនង និងផលប្រយោជន៍ដែលបានពីព្រះរាជគម្រោងឧបត្ថម្ភអាហារូបករណ៍ ដែលនិស្សិតខ្មែរនៅសាកលវិទ្យាល័យមហាសារ៉ាខាមទទួលបានក៏ដូចជានៅសាកលវិទ្យាល័យដទៃទៀតក្នុងប្រទេសថៃ។ ពួកគេទទួលបានសម្របខ្លួនក្នុងឋានៈខ្លួនជាអ្នកឆ្លងដែនដែលមកសិក្សានៅក្រៅប្រទេស ដើម្បីទទួលបាននូវចំណេះដឹង ចំណេះធ្វើ និងបទពិសោធ។

យើងសង្ឃឹមថា ក្រោយពីការសិក្សាប្រយោជន៍និងការសម្របខ្លួនរបស់និស្សិតខ្មែរនៅសាកលវិទ្យាល័យមហាសារ៉ាខាមហើយ កិច្ចការស្រាវជ្រាវនេះនឹងអាចជាប្រយោជន៍ដល់និស្សិតខ្មែរដែលនឹងមកបន្តការសិក្សានៅពេលក្រោយទៀតបានពិសេសទាក់ទងនឹងការសម្របខ្លួនក្នុងសង្គមថ្មី។ ក្តីរំពឹងមួយទៀត សូមឲ្យព្រះរាជគម្រោងឧបត្ថម្ភបន្តនៅជួយផ្តល់អាហារូបករណ៍ដល់និស្សិតខ្មែរបន្តទៀត ដើម្បីជួយកសាងធនធានមនុស្សរបស់ប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសទន្លេមេគង្គ មានសមត្ថភាពក្នុងធ្វើការងារនិងអភិវឌ្ឍខ្លួនបានទៅថ្ងៃអនាគត។

# ឯកសារពិគ្រោះ

- ภิญโญ สาธร , (2521) หลักการศึกษา, ครั้งที่ ๑, กทม. สำนักพิมพ์สุภา

- สุรพงษ์ ปนาทกูล, (2526) ความรู้เบื้องต้นทางการศึกษา,ครั้งที่ ๑,กทม. โรงพิมพ์และทำปกเจริญ

- ทวิป อภิสิทธิ์ (2554) การศึกษาตามอัธยาศัย,ครั้งที่๑, กทม. สำนักพิมพ์จุฬาลงกรณ์มหาวิทยาลัย

- อนุสรณ์ สมตระกูล (2531) การปรับตัวของนักเรียนที่มีความบกพร่องทางการได้ยิน อายุระหว่าง ๑๕-๒๐ ปี ที่เรียนร่วมห้องเรียนเดียวกับเด็กปกติ ในกรุงเทพมหานคร, วิทยานิพนพ์มหาวิทยาลัยศรีนครินวิโรฒ

- Kneller, F George. Educational Anthropology: An Introduction. Hoboken, Nj, U.s.a. 1965

- George Spendler. Presto! Magic for the Beginner.Dover Publications, 1977

- Gillmer, B. Von, Haller and other. Industrial and Organizational Psychology. New York, McGraw-Hill Book Company, 1971. 682 p.

- John Dewey. Experience and Educaiton. Kappa Delta Pi, 1938

- Lazarus, Richard S. Patterns of Adjustment and Human Effectiveness. New York, McGraw-Hill Book Company, 1969. 680 p.

- Rogers, C.R. “The Organization of Personality” American Psychologists. 2 : 358-368 December, 1947

- Theodore Schultz. Investment in Human Capital: The Role of Education and of Research, New York: Free Press,1971

- http://www.kampongchheuteal.org